## សមភាពនៃភាគី (equality of arms)

សញ្ញាណស្ដីពី សមភាពរវាងភាគី គឺជាវិធានទូទៅនៃច្បាប់នីតិវិធី។ វាមានប្រភពពីកុំមុនឡ (common law) ដែលជានីតិវិធីដេញដោល (adversary tradition) តទល់រវាងភាគីក្នុងដំណើរការក្ដីព្រហ្មទណ្ឌ។

សមភាពរវាងភាគី តម្រូវឲ្យភាគីនៃរឿងក្ដីមានលទ្ធភាព និងឱកាសដូចគ្នា។ សមភាពរវាងភាគី ជាធាតុផ្សំមួយនៃសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌។ មានយុត្តិសាស្ត្រជាច្រើនរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (European Court of Human Rights) ពាក់ព័ន្ធនឹងសិទ្ធិសមភាពនៃភាគី។ ក្នុងសំណុំរឿងមួយ តុលាការបានបកស្រាយយ៉ាងសាមញ្ញថា បើភាគីចោទប្រកាន់មានឱកាសក្នុងការបង្ហាញសំណុំរឿង ជនត្រូវចោទក៏មានសិទ្ធិ ត្រូវបានដឹងដែរ (*Hopfinger v. Austria*)។

សិទ្ធិសមភាពរវាងភាគីអនុវត្តផងដែរ ក្នុងដំណាក់កាលស៊ើបអង្កេត ដូចជាសិទ្ធិមានអ្នកតំណាង (right to legal assistance) ក្នុងពេលស៊ើបអង្កេត ការបញ្ចេញភស្តុតាង (disclosure) ដើម្បីជាមូលដ្ឋានត្រៀមការពារខ្លួន (right to effective defence) ឬ សម្រាប់ការប្ដឹងអំពីភាពស្របច្បាប់នៃការឃាត់ខ្លួន (*harbea corpus*)។

លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជា ICTY មិនមានចែងអំពីគោលការណ៍សមភាពទេ ហើយអង្គជំនុំជម្រះ បានព្យាយាមបកស្រាយបញ្ចូលគោលការណ៍នេះ។ ជាបទពិសោធន៍ ICC ក្នុងលក្ខន្តិកៈរបស់ខ្លួន បានចែងយ៉ាងច្បាស់ក្នុងមាត្រា៦៧ អំពីគោលការណ៍នេះ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 311-312) ។

**ខ្លឹមសារបន្ថែម៖** មាត្រា១៤ (៣) នៃកតិកាសញ្ញា ស្ដីពីសិទ្ធិប្រជាពលរដ្ឋ៖

ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖

(ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។ ................